ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៧៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៥ ៦២៥នាក់ នៃរោងចក្រ សហគ្រាសទាំង២៧ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង២៧ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២១

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ២៧ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 3 |
| 1 | ក្រុមហ៊ុន ម៉ាកស៍វ្វូ ថេកស្ថាយ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន តេហ្វូអាំប្រេឡាខូអិលធីឌី | កណ្តាល |
| 3 | ក្រុមហ៊ុន ហ្គោលឌិន ចេន ប្លាស្ទីក | កណ្តាល |
| ខ. វិស័យទេសចរណ៍ | | 24 |
| 4 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ហ្វីដឡាយហ៍ ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត | ភ្នំពេញ |
| 10 | ក្រុមហ៊ុន អាយរ៉ុន ឆេហ្វ អេហ្វ&ប៊ី (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន អេឡើអេកស្ពីឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុន រ៉េមប៊ូធិនរីសតខេមបូឌាន | ភ្នំពេញ |
| 13 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 14 | ក្រុមហ៊ុន ស្តារី អ៊ីម៉ិច ខូ អិលធីឌី (សណ្ឋាគារស្តារីអង្គរ) | សៀមរាប |
| 15 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 16 | ក្រុមហ៊ុន កូបេ យៃកែននីស វែស្ទូវែន | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ផ្ទះសំណាក់បាបែល | សៀមរាប |
| 18 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 19 | ក្រុមហ៊ុន អេរីតាស II | សៀមរាប |
| 20 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 21 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 22 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |
| 23 | ក្រុមហ៊ុន ដឹ អេរៀរី | សៀមរាប |
| 24 | ក្រុមហ៊ុន រេសថីរេន ខូឡិចហ្សិន | សៀមរាប |
| 25 | ក្រុមហ៊ុន ញ្ញូវ រីវើរ សាយ | សៀមរាប |
| 26 | សណ្ឋាគារ ហិមា ប៊ូទិក | សៀមរាប |
| 27 | ក្រុមហ៊ុន ឡាយ ហ្វូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |